# ស្ដីពីការបញ្ចប់វិធានការពិសេសពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិស្នាក់នៅចំពោះអ្នកមានការពិបាកនឹងត្រឡប់ទៅប្រទេសខ្លួនវិញ ដោយសារឥទ្ធិពលនៃការរាតត្បាតនៃជម្ងឺឆ្លងកូវីដ១៩

ថ្ងៃទី 31 ខែឧសភា ឆ្នាំ2022
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន
Immigration Services Agency of Japan

## វិធានការពីពេលនេះទៅ

○ ដោយពិចារណាមើលទៅលើស្ថានភាពអ្នកចេញពីប្រទេសជប៉ុនកំពុងមានកំណើន ជាអាទិ៍ សម្រាប់ជនបរទេសដែលមានការទទួលស្គាល់នូវការស្នាក់នៅពិសេស យើងខ្ញុំមានវិធានការសម្រាប់ការវិលត្រឡប់ទៅប្រទេសខ្លួនវិញដូចតទៅ ទៅតាមកម្លុងពេលអាចស្នាក់នៅដែលមានបច្ចុប្បន្ន។

## ①អ្នកដែលមានកម្លុងពេលអាចស្នាក់នៅរហូតដល់ថ្ងៃទី29 ខែមិថុនា ឆ្នាំ2022

អនុញ្ញាតឱ្យពន្យារកម្លុងពេលស្នាក់នៅដូចខាងក្រោមនេះ។

ក) អ្នកស្នាក់នៅដែលមានលក្ខណៈសម្បត្តិ "សកម្មភាពពិសេស (6ខែ) ជាអាទិ៍" : "សកម្មភាពពិសេស (4ខែ)"

ខ) អ្នកស្នាក់នៅដែលមានលក្ខណៈសម្បត្តិ "ស្នាក់នៅរយៈពេលខ្លី (90ថ្ងៃ)" : "ស្នាក់នៅរយៈពេលខ្លី (90ថ្ងៃ)"

កំណត់ 1) អាចបន្តការធ្វើការងារក្នុងកម្រិតដែលបានទទួលការអនុញ្ញាតបច្ចុប្បន្ននេះបាន។

កំណត់ 2) នៅពេលសុំបន្តលើកក្រោយ នឹងទទួលនូវការអនុញ្ញាតនូវ "សកម្មភាពពិសេស (4ខែ)" ឬ "ស្នាក់នៅរយៈពេលខ្លី (90ថ្ងៃ)" "តែលើកនេះប៉ុណ្ណោះ"។

## ② អ្នកដែលមានកម្លុងពេលអាចស្នាក់នៅរហូតដល់ក្រោយថ្ងៃទី29 ខែមិថុនា ឆ្នាំ2022

អនុញ្ញាតនូវការពន្យារកម្លុងពេលស្នាក់នៅដូចខាងក្រោមនេះ "តែលើកនេះប៉ុណ្ណោះ"។

ក) អ្នកស្នាក់នៅដែលមានលក្ខណៈសម្បត្តិ "សកម្មភាពពិសេស (6ខែ)" ជាអាទិ៍ : "សកម្មភាពពិសេស (4ខែ)"

ខ) អ្នកស្នាក់នៅដែលមានលក្ខណៈសម្បត្តិ "ស្នាក់នៅរយៈពេលខ្លី (90ថ្ងៃ)" : "ស្នាក់នៅរយៈពេលខ្លី (90ថ្ងៃ)"

កំណត់ 1) អាចបន្តការធ្វើការងារក្នុងកម្រិតដែលបានទទួលការអនុញ្ញាតបច្ចុប្បន្ននេះបាន។

កំណត់ 2) ការអនុញ្ញាតនូវការស្នាក់នៅដោយមូលហេតុពិបាកត្រឡប់ទៅវិញ អាចបានតែលើកនេះប៉ុណ្ណោះ។ សូមរៀបចំត្រឡប់ទៅវិញក្នុងកម្លុងពេលដែលបានទទួលការអនុញ្ញាតលើកនេះ។

កំណត់ 3) ក្នុងករណីដែលកម្លុងពេលអាចស្នាក់នៅពាក់ព័ន្ធនឹងការអនុញ្ញាតខាងលើនេះត្រូវបានបញ្ចប់ មិនអនុញ្ញាតការពន្យារកម្លុងពេលបានទេ។

## ③ អ្នកដែលចង់បន្តការស្នាក់នៅដោយមូលហេតុពិបាកត្រឡប់ទៅវិញថ្មី

សម្រាប់តែករណីដែលកម្លុងពេលអាចស្នាក់នៅនៃលក្ខណៈសម្បត្តិស្នាក់នៅមាន ដល់ត្រឹមថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2022 មានការទទួលស្គាល់នូវវិធានការពិសេស② ខាងលើនេះ "តែលើកនេះប៉ុណ្ណោះ"។

កំណត់ ) អនុញ្ញាតជូនយ៉ាងវែង 1ឆ្នាំ ស្ដីពី "សកម្មភាពពិសេស (ជំនួយរក្សាការងារ)" (※"តែលើកនេះប៉ុណ្ណោះ")។

**※អ្នកដែលទទួលបាននូវការអនុញ្ញាត "តែលើកនេះប៉ុណ្ណោះ" សូមដាក់ "លិខិតបញ្ជាក់"។**

# អ្នកដែលជាមុខសញ្ញានៃការបញ្ចប់វិធានការពិសេស

| | អ្នកដែលជាមុខសញ្ញា | វិធានការពីមុន | វិធានការថ្មី |
|---|---|---|---|
| 1 | អតីតសិក្ខាកាមហ្វឹកហ្វឺនជំនាញ | សកម្មភាពពិសេស(6ខែ, ពិបាកត្រឡប់ទៅវិញ, អាចធ្វើការបាន) | សកម្មភាពពិសេស(4ខែ, ពិបាកត្រឡប់ទៅវិញ, អាចធ្វើការបាន) |
| 2 | អតីតនិស្សិត | សកម្មភាពពិសេស(6ខែ, ពិបាកត្រឡប់ទៅវិញ, អាចធ្វើការបានក្នុងមួយអាទិត្យត្រឹម 28ម៉ោង) | សកម្មភាពពិសេស(4ខែ, ពិបាកត្រឡប់ទៅវិញ, អាចធ្វើការបានក្នុងមួយអាទិត្យត្រឹម 28ម៉ោង) |
| 3 | អតីតអ្នកស្នាក់នៅរយៈពេលវែង និងមធ្យម | សកម្មភាពពិសេស(6ខែ, ពិបាកត្រឡប់ទៅវិញ, មិនអាចធ្វើការបានទេ)(※) | សកម្មភាពពិសេស(4ខែ, ពិបាកត្រឡប់ទៅវិញ, មិនអាចធ្វើការបានទេ)(※) |
| 4 | អតីតអ្នកស្នាក់នៅរយៈពេលខ្លី | ស្នាក់នៅរយៈពេលខ្លី(90ថ្ងៃ, ពិបាកត្រឡប់ទៅវិញ, មិនអាចធ្វើការបានទេ)(※) | ស្នាក់នៅរយៈពេលខ្លី(90ថ្ងៃ, ពិបាកត្រឡប់ទៅវិញ, មិនអាចធ្វើការបានទេ)(※) |
| 5 | អ្នកដែលជាមុខសញ្ញានៃជំនួយរក្សាការងារ | សកម្មភាពពិសេស(យ៉ាងវែង 1ឆ្នាំ, ជំនួយរក្សាការងារ, អាចធ្វើការបាន) | សកម្មភាពពិសេស(យ៉ាងវែង 1ឆ្នាំ, ជំនួយរក្សាការងារ, អាចធ្វើការបាន)<br>កំណត់) នៅពេលពន្យារគឺ 4ខែ |
| 6 | កម្មសិក្សា<br>(សេចក្តីជូនដំណឹងលេខ 9)<br>បុគ្គលិកបរទេសវិស័យកម្មន្តសាល<br>(សេចក្តីជូនដំណឹងលេខ 42) | សកម្មភាពពិសេស(6ខែ, ពិបាកត្រឡប់ទៅវិញ, អាចធ្វើការបាន) | សកម្មភាពពិសេស(4ខែ, ពិបាកត្រឡប់ទៅវិញ, អាចធ្វើការបាន) |
| 7 | អតីតអ្នកជំនួយការងារតាមផ្ទះសម្រាប់ជនបរទេស | សកម្មភាពពិសេស(6ខែ, ពិបាកត្រឡប់ទៅវិញ, មិនអាចធ្វើការបានទេ)(※) | សកម្មភាពពិសេស(4ខែ, ពិបាកត្រឡប់ទៅវិញ, មិនអាចធ្វើការបានទេ)(※) |

※ អាចធ្វើការត្រឹម 28ម៉ោងក្នុងមួយអាទិត្យបាន តាមរយៈការទទួលការអនុញ្ញាតឱ្យធ្វើសកម្មភាពពិសេសក្រៅលក្ខណៈសម្បត្តិស្នាក់នៅ